**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារចម្លើយ[1]

## ដើមចោទ

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

## ចុងចម្លើយ

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## អ្នកតំណាងដោយអាណត្តិ

លោក/លោកស្រីមេធាវី ៖ B

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖..............................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖...............................................

លេខទូរស័ព្ទ៖...................................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................[2]

---

[1] ឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការជាលើកដំបូង ហៅថា "ឯកសារចម្លើយ"។ នៅក្នុងឯកសារនេះនឹងត្រូវសរសេរអំពី ① ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរនៅក្នុងពាក្យបណ្តឹង ② ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និង ③ អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង (កថាខណ្ឌទី៣ មាត្រា ១០១នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] មាត្រា ២៤៩ និង មាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីកន្លែងបញ្ជូន មិនមែនជាកាតព្វកិច្ចទេ។ ប្រសិនបើមិនបានសរសេរអំពីទីកន្លែងបញ្ជូន ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍។ ដូច្នេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយចង់ធ្វើការបញ្ជូនទៅទីកន្លែងណាផ្សេងក្រៅពីលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍ ចាំបាច់ត្រូវសរសេរអំពីកន្លែងបញ្ជូនចូលទៅក្នុងលិខិតលាយលក្ខណ៍អក្សរ ដូចជា ឯកសារចម្លើយជាអាទិ៍។

**សូមគោរពជូន**

**លោក ៗ ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u>**៖ សុំដាក់**ឯកសារចម្លើយដើម្បីឆ្លើយតប**នឹងពាក្យបណ្ដឹងចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៩ របស់ឈ្មោះ X

**<u>យោង</u>**៖-មាត្រា **១០១ កថាខណ្ឌទី ៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី០១ ខែ កុម្ភៈ ឆ្នាំ ២០១៩

## ក. ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

(១) ច្រានចោលការទាមទារ[3]ទាំងអស់របស់ដើមចោទ។

(២) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

## ខ. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង

### ខ.១. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពីការបង្កើតកិច្ចសន្យាលក់ទិញនៅក្នុងពាក្យបណ្ដឹង

**ខ.១.១.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.១."** នៃពាក្យបណ្ដឹង៖ ចុងចម្លើយទទួលស្គាល់ ។

**ខ.១.២.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.២."** នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

### ខ.២. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពីអង្គហេតុពាក់ព័ន្ធនៃចំណុច "គ" នៅក្នុងពាក្យបណ្ដឹង

**ខ.២.១.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"គ.១."** នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

---

[3] សិទ្ធិដែលដើមចោទកំពុងតែទាមទារមាន ២ ( ១. សិទ្ធិទាមទារឲ្យប្រគល់វត្ថុនៃការលក់ទិញដោយផ្អែកតាមកិច្ចសន្យាលក់ទិញ និង ២. សិទ្ធិទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលដោយផ្អែកតាមកិច្ចសន្យាលក់ទិញ) ដូច្នេះហើយនៅពេលដែលទាមទារឲ្យច្រានចោលនូវចំណុចទាំងអស់នោះ ត្រូវសរសេរពាក្យថា "ទាំងអស់" ។

**ខ.២.២.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "**គ.២.**" នៃពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ ។

## គ. អង្គហេតុតវ៉ា

### គ.១. ការរំលាយកិច្ចសន្យាដោយសងប្រាក់កក់[4]

**គ.១.១.** នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៨ នៅពេលដែលចុះ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ជាមួយចុងចម្លើយ ដើមចោទបានព្រមព្រៀងបង់ប្រាក់កក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ហើយបានប្រគល់ប្រាក់នោះឲ្យទៅចុងចម្លើយ។

[4] អង្គហេតុចម្បងនៃការរំលាយកិច្ចសន្យាដោយសងប្រាក់កក់ ៖ មាត្រា ៥១៨ មាត្រា ៩១៥ មាត្រា ៩០៩ កថាខណ្ឌទី ១ ។ ដោយសារតែភាពចាំបាច់ដំបូងគឺ " អ្នកទិញបានបង់ប្រាក់កក់ទៅឲ្យអ្នកលក់" (មាត្រា ៥១៨) ដូច្នេះហើយ ចាំបាច់ត្រូវធ្វើការអះអាងថា ៖ ① អ្នកទិញបានព្រមព្រៀងជាមួយអ្នកលក់អំពីការប្រគល់ប្រាក់កក់នៃកិច្ចសន្យាលក់ទិញ ② អ្នកទិញបានប្រគល់ប្រាក់កក់ដោយផ្អែកលើកចំណុច ① ឲ្យទៅអ្នកលក់។ បន្ទាប់មកទៀត ភាពចាំបាច់គឺ "ការសងប្រាក់ស្មើនឹងពីរដងនៃប្រាក់កក់" (មាត្រា ៥១៨) ហេតុនេះ ចាំបាច់ត្រូវធ្វើការអះអាងថា ៖ ③ អ្នកទិញបានធ្វើសំណើផ្តល់ប្រាក់កក់ជាក់ស្តែងចំនួន ២ដង នៃប្រាក់កក់ឲ្យទៅអ្នកទិញ (យោងតាម Footnote 5 ដែលសរសេរខាងក្រោមផងដែរ)។ ហើយ ដោយសារតែភាពចាំបាច់នៅពេលដែលធ្វើការរំលាយកិច្ចសន្យា គឺ " ការបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាទៅភាគីម្ខាងទៀត" (មាត្រា ៩១៥ កថាខណ្ឌទី ១ មាត្រា ៩០៩ កថាខណ្ឌទី ១) ហេតុនេះ ចាំបាច់ត្រូវធ្វើការអះអាងថា ៖ ④អ្នកលក់បានបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាទៅអ្នកទិញ។ យ៉ាងណាមិញ ដោយសារតែ ការបង្ហាញឆន្ទៈនឹងកើតមានអានុភាពនៅពេលដែលបានទៅដល់ភាគីម្ខាងទៀត (មាត្រា ៣១០ កថាខណ្ឌទី ២) ដូច្នេះហើយ នៅក្នុងរឿងក្តីនេះ ត្រូវធ្វើការអះអាងអំពី ការបានបង្ហាញឆន្ទៈដែលបានធ្វើឡើងនៅចំពោះមុខដើមចោទដែលជាភាគីម្ខាងទៀត។

**គ.១.២.** នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៨ចុងចម្លើយបានធ្វើសំណើផ្តល់[5] ប្រាក់ជាក់ស្តែងចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកនៅផ្ទះរបស់ដើមចោទ (ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ) ហើយបានបង្ហាញឆន្ទៈអំពីការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ទៅកាន់ដើមចោទ។

**ដូច្នេះហើយ ដោយសារតែចុងចម្លើយបាន "រំលាយកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដោយផ្អែកតាមមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណី ហេតុនេះ ចុងចម្លើយពុំមានទំនួលខុសត្រូវក្នុងការអនុវត្ត "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ទេ ។**

## ឃ. ភស្តុតាង

១. លិខិតទទួលប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៨ **(ភស្តុតាង$Y_1$)**

---

[5] ដោយសារតែអ្នកលក់អាចរំលាយកិច្ចសន្យាលក់ទិញដោយ "**សងប្រាក់**ស្មើនឹងពីរដងនៃប្រាក់កក់" (មាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណី) ដូច្នេះ បើសិនជាអ្នកលក់គ្រាន់តែជូនដំណឹងអំពីការបញ្ចប់នូវការរៀបចំសង និង ដាស់តឿនទៅអ្នកទិញឲ្យទទួលការសងនូវទឹកប្រាក់ ២ដង នៃចំនួនប្រាក់កក់ តែប៉ុណ្ណឹង គឺមិនទាន់មានភាពគ្រប់គ្រាន់ទេ (មិនអាចរំលាយកិច្ចសន្យាលក់ទិញបានទេ) ។

តាមមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណី ចែងថា "អ្នកលក់សងប្រាក់ស្មើនឹងពីរដងនៃប្រាក់កក់" គឺជាការចែងអំពីសកម្មភាពរបស់អ្នកលក់តែប៉ុណ្ណោះ ដូច្នេះហើយ ចំពោះឥរិយាបថរបស់អ្នកទិញដែលឆ្លើយតបទៅកាន់សកម្មភាពរបស់អ្នកលក់វិញ (ទទួលយក ឬ យ៉ាងណា? ) គឺពុំមានបញ្ហាអ្វីឡើយ។ ដូច្នេះហើយ ចំពោះអ្នកលក់ គឺគ្រាន់តែអះអាងអំពី "ការធ្វើសំណើផ្តល់ប្រាក់ជាក់ស្តែង" ចំនួន ២ដង នៃប្រាក់កក់ គឺគ្រប់គ្រាន់។

នៅក្នុងរឿងក្តីនេះ ដើមចោទដែលជាអ្នកទិញមិនទាន់បានទទួលប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកទេ ប៉ុន្តែ ចុងចម្លើយដែលជាអ្នកលក់បានធ្វើសំណើផ្តល់ ប្រាក់ជាក់ស្តែងចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកនៅផ្ទះរបស់ដើមចោទ ដូច្នេះហើយ គឺអាចធ្វើការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ផ្អែកតាមមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណី។

យ៉ាងណាមិញ បើទោះបីជា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ត្រូវបានរំលាយផ្អែកតាមមាត្រា ៥១៨ នៃក្រមរដ្ឋប្បវេណីក៏ដោយ ក៏សិទ្ធិទាមទារឲ្យបង់ប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកដែលដើមចោទមានចំពោះចុងចម្លើយ មិនរលត់ឡើយ ( នៅក្នុងមូលហេតុនៃការរលត់កាតព្វកិច្ចនៃមាត្រា ៤៣៣ នៃក្រមរដ្ឋប្បវេណី មិនមានបញ្ចូលនូវ "សំណើផ្តល់ការសង" ទេ។ ដរាបណា ចុងចម្លើយមិនសង ឬ មិនតម្កល់ (មាត្រា ៤៥៧ នៃក្រមរដ្ឋប្បវេណី) ទេ កាតព្វកិច្ចរបស់ចុងម្លើយមិនរលត់ឡើយ ) ដូច្នេះ ហើយដើមចោទអាចទាមទារម្តងទៀតឲ្យចុងចម្លើយបង់ប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក។

សូម **លោកចៅក្រម** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩

**អ្នកតំណាងដោយអាណត្តិ**

B

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-ឯកសារចម្លងនៃឯកសារចម្លើយ "ចំនួន ០២ ច្បាប់"